＜カンボジア語＞

អ្នកជិតខាងដ៏ល្អដែលអ្នកអាចពឹងផ្អែកបាន។

# រីករាយ! ជីវិតរស់នៅក្នុងក្រុង Aikawa

សមាគមអ្នកជិតខាងអាចធ្វើឱ្យអ្នកកាន់តែស្រឡាញ់ទីក្រុងនេះ។

សមាគមអ្នកជិតខាង គឺជាសហគមន៍មូលដ្ឋានដ៏ស្និទ្ធស្នាលមួយ ដែលជួយពង្រឹងទំនាក់ទំនងរវាងប្រជាពលរដ្ឋ តាមរយៈសកម្មភាពត្រៀមបង្ការគ្រោះមហន្តរាយ និងព្រឹត្តិការណ៍សង្គមផ្សេងៗ ដែលបង្កើតនូវកន្លែងរស់នៅមួយប្រកបដោយសុវត្ថិភាព និងផាសុកភាព។ ការចូលរួមជាមួយសមាគមនេះនឹងធ្វើឱ្យជីវិតរស់នៅក្នុងក្រុង Aikawa កាន់តែមានភាពសប្បាយរីករាយ។

## សកម្មភាពរបស់សមាគមអ្នកជិតខាង

ការគាំទ្រជីវិតរស់នៅប្រចាំថ្ងៃរបស់យើង។ សមាគមអ្នកជិតខាងធ្វើការដើម្បីពង្រឹងទំនាក់ទំនងរវាងប្រជាពលរដ្ឋ និងអនុវត្តគំនិតផ្តួចផ្តើមផ្សេងៗ ដើម្បីកសាងសហគមន៍មួយប្រកបដោយសុវត្ថិភាពនិងផាសុកភាព។

### សកម្មភាពពង្រឹងសុវត្ថិភាពនិងទប់ស្កាត់បទល្មើសនៅក្នុងសហគមន៍



សមាគមអ្នកជិតខាងតែងអនុវត្តសកម្មភាពទប់ស្កាត់បទល្មើសផ្សេងៗ ដូចជា ការដើរល្បាត ជាដើម។ បន្ថែមពីនេះ ទំនាក់ទំនងជិតស្និទ្ធប្រចាំថ្ងៃនៅក្នុងសហគមន៍ជួយទប់ស្កាត់ឧប្បត្តិហេតុផ្សេងៗ ដូចជា អំពើចោរកម្ម (ការគាស់ផ្ទះ) ដែលធ្វើឱ្យមានប្រសិទ្ធភាពសម្រាប់សុវត្ថិភាពក្នុងមូលដ្ឋានផងដែរ។

### 【ការចែករំលែកព័ត៌មាននៅក្នុងមូលដ្ឋាន 】 សកម្មភាពទំនាក់ទំនងសាធារណៈ




ព័ត៌មានប្រចាំមូលដ្ឋាននិងប្រចាំទីក្រុងត្រូវបានចែករំលែកតាមរយៈសារាចរព័ត៌មាននិងក្តារប្រកាសព័ត៌មាននានា ដើម្បីឱ្យប្រជាពលរដ្ឋបានជ្រាបជាដំណឹង។

### 【ការរក្សាអនាម័យក្នុងសហគមន៍ 】 សកម្មភាពសម្អាត និងកែលម្អបរិស្ថាន

ដោយមានកិច្ចសហការជាមួយអាជ្ញាធរក្រុង យុទ្ធនាការផ្សេងៗ ដូចជា “យុទ្ធនាការសម្អាតសំរាមឱ្យស្មើនឹងសូន្យ” ត្រូវបានអនុវត្ត រួមជាមួយកិច្ចខិតខំប្រឹងប្រែងប្រចាំថ្ងៃ ដើម្បីរក្សាតំបន់មូលដ្ឋានឱ្យមានអនាម័យ និងគួរឱ្យរស់នៅ។



## 【ការត្រៀមលក្ខណៈសម្រាប់ហេតុការណ៍បន្ទាន់ 】

## សកម្មភាពបង្ការគ្រោះមហន្តរាយ



នៅក្នុងព្រឹត្តិការណ៍គ្រោះមហន្តរាយ ការជួយឧបត្ថម្ភគាំទ្រគ្នាទៅវិញទៅមកនៅក្នុងសហគមន៍គឺជារឿងសំខាន់បំផុត។ យើងអនុវត្តការហ្វឹកហាត់ត្រៀមបង្ការគ្រោះមហន្តរាយ និងរក្សានូវស្តុកគ្រឿងផ្គត់ផ្គង់បន្ទាន់ ដើម្បីធានាបាននូវការត្រៀមខ្លួនជាស្រេច ប្រសិនបើមានគ្រោះមហន្តរាយកើតឡើង។

## សកម្មភាពសប្បុរសធម៌ដើម្បីសុខុមាលភាពសហគមន៍



យើងប្តេជ្ញាចិត្តក្នុងការកសាងសហគមន៍មួយប្រកបដោយសុវត្ថិភាពនិងការគាំទ្រដែលអ្នករាល់គ្នាអាចរស់នៅដោយស្ងប់ចិត្ត។ សកម្មភាពរបស់យើងរួមមានការចុះសួរសុខទុក្ខប្រជាពលរដ្ឋវ័យចំណាស់ និងការគាំទ្រដល់គំនិតផ្តួចផ្តើមរៃអង្គាសប្រាក់សប្បុរសធម៌។

## ទំនាក់ទំនងសហគមន៍ និងសកម្មភាពរៃអង្គាសប្រាក់

យើងរៀបចំពិធីបុណ្យនិងព្រឹត្តិការណ៍សហគមន៍នានាដែលលើកកម្ពស់ការប្រាស្រ័យទាក់ទង និងពង្រឹងចំណងមិត្តភាពក្នុងមូលដ្ឋាន។ ការចូលរួមក្នុងសកម្មភាពទាំងនេះផ្តល់នូវឱកាសដ៏មានតម្លៃ ក្នុងការកសាងទំនាក់ទំនងផ្ទាល់មុខប្រកបដោយអត្ថន័យរវាងប្រជាពលរដ្ឋ។





### តើប្រាក់វិភាគទានសមាគមអ្នកជិតខាងត្រូវបានយកទៅប្រើប្រាស់យ៉ាងដូចម្តេច?

ប្រាក់វិភាគទានសមាគមត្រូវបានយកទៅប្រើប្រាស់ដើម្បីគាំទ្រដល់គំនិតផ្តួចផ្តើមផ្សេងៗក្នុងសហគមន៍ ដូចជា ព្រឹត្តិការណ៍ក្នុងមូលដ្ឋាន សកម្មភាពត្រៀមបង្ការគ្រោះមហន្តរាយ និងកម្មវិធីជួយសង្គ្រោះគ្នាទៅវិញទៅមក។ ដោយសារអាទិភាពនិងចំណាយនានាអាចមានភាពខុសប្លែកគ្នាពីសហគមន៍មួយទៅសហគមន៍មួយទៀត សូមទាក់ទងសមាគមអ្នកជិតខាងក្នុងមូលដ្ឋានរបស់អ្នកសម្រាប់ព័ត៌មានជាក់លាក់។



### តើត្រូវធ្វើដូចម្តេចដើម្បីចូលរួមជាសមាជិកសមាគមអ្នកជិតខាង?

ដើម្បីចូលរួម សូមទាក់ទងប្រធានសមាគមអ្នកជិតខាង ឬតំណាងប្រជាពលរដ្ឋតាមប្លុករបស់អ្នក។ ប្រសិនបើអ្នកមិនស្គាល់ព័ត៌មានទំនាក់ទំនងរបស់សមាគមក្នុងមូលដ្ឋានរបស់អ្នកទេ សូមទាក់ទងទៅការិយាល័យលើកកម្ពស់កិច្ចសហការឌីជីថល ដើម្បីទទួលបានជំនួយ។

## តស់! រួមគ្នាកសាងទីក្រុង AIKAWA ដ៏ល្អប្រពៃទាំងអស់គ្នា!

សកម្មភាពរបស់សមាគមអ្នកជិតខាងមានតួនាទីយ៉ាងសំខាន់ក្នុងការគាំទ្រដល់ជីវិតរស់នៅប្រចាំថ្ងៃ សុវត្ថិភាព និងភាពស្ងប់ចិត្ត ដែលជាញឹកញាប់រឿងទាំងនេះត្រូវបានមើលរំលង។ ក្នុងគ្រាអាសន្ន ការជួយសង្គ្រោះគ្នាទៅវិញទៅមក និងការគាំទ្រក្នុងសហគមន៍ គឺជារឿងសំខាន់ខ្លាំងណាស់។ យើងសូមលើកទឹកចិត្តឱ្យអ្នកចូលរួមជាមួយសមាគមអ្នកជិតខាងក្នុងមូលដ្ឋានរបស់អ្នក។

**ការសាកសួរព័ត៌មានអំពីការចូលជាសមាជិក និងសកម្មភាពរបស់សមាគមអ្នកជិតខាង**

សម្រាប់ការសាកសួរព័ត៌មានអំពីការចូលជាសមាជិក ឬសកម្មភាពរបស់សមាគមអ្នកជិតខាង សូមទាក់ទងការិយាល័យលើកកម្ពស់កិច្ចសហការឌីជីថលនៃនាយកដ្ឋានលើកកម្ពស់កិច្ចសហការៈ 046-285-6937 (ខ្សែទូរសព្ទផ្ទាល់)។

**សូមដាក់ពាក្យសុំចូលរួមជាសមាជិកនៅទីនេះ។**